# សហគមន៍មានសុវត្ថិភាព ៥

adpc

មិថុនា២០០៩


# កម្មវិធីសុវត្ថិភាពទឹកជំនន់នៅតាមសាលារៀន

## ការកសាងសមត្ថភាពគ្រូបង្រៀន និងសិស្សានុសិស្ស អំពីការកាត់បន្ថយគ្រោះភ័យនៃទឹកជំនន់


### ពត៌មានសង្ខេប

ករណីសិក្សានេះពណ៌នាពីបទពិសោធន៍នានា ដែលទទួលបានពីការអនុវត្តន៍សកម្មភាពសាកល្បងលើយុទ្ធនាការផ្សព្វផ្សាយចំណេះដឹងអំពីកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ នៅក្នុងពីរសាលារៀននៅប្រទេសកម្ពុជា ក្រោមគម្រោងកម្មវិធីពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS) ដែលអនុវត្តដោយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRCS) និងគាំទ្រជំនួយបច្ចេកទេសពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC) ។ គម្រោងនេះជាផ្នែកមួយនៃយុទ្ធនាការផ្សព្វផ្សាយចំណេះដឹងជាសាធារណៈដ៏ធំមួយ ដែលបានបង្កើតឡើងនៅក្រោមកម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ (FEMS) និងស្វែងរកនូវដំណោះស្រាយចំពោះតម្រូវការនានារបស់អ្នក ដែលងាយរងគ្រោះបំផុត ដែលជាញឹកញាប់ពួកគាត់ទាំងនោះ មិនត្រូវបានគេយកចិត្តទុកដាក់នៅក្នុងចំណោមប្រជាពលរដ្ឋក្នុងសហគមន៍ ពិសេសគឺកុមារ។ ករណីសិក្សានេះផ្តល់ការណែនាំពីវិធីផ្សេងៗ ដែលអាចឱ្យសិស្សានុសិស្សអនុវត្តតាមបានដើម្បីបង្កើននូវចំណេះដឹងលើការកាត់បន្ថយគ្រោះភ័យនៃទឹកជំនន់នៅតាមសាលារៀន និងកម្មវិធីសុវត្ថិភាពកុមារផងដែរ។


### ខ្លឹមសាររឿង


- ជំហានសម្រាប់អនុវត្តសំខាន់ៗ ២
- មេរៀនបទពិសោធន៍ដែលទទួលបាន ៣
- សេចក្តីសន្និដ្ឋាន និង ជំហានបន្ត ៣




*ក្មេងៗសិស្សសាលាចូលរួមក្នុងការឆ្លើយសំណួរប្រលងប្រជែងទាក់ទងនឹងការត្រៀមបង្ការគ្រោះទឹកជំនន់ ដែលជាផ្នែកមួយនៃកម្មវិធីសុវត្ថិភាពពីគ្រោះទឹកជំនន់តាមសាលារៀន ។*

*គោលគំនិតសម្រាប់បញ្រ្ជាបការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់តាមរយៈសាលា ដែលកើតពីយុទ្ធនាការផ្សព្វផ្សាយចំណេះដឹងជាសាធារណៈ បានអនុវត្តកាលពីខែមិថុនា ២០០៥ ស្ថិតក្រោមគម្រោង "ពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS)" ដែលអនុវត្តដោយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRCS) និងគាំទ្រជំនួយបច្ចេកទេសពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC) ។ គម្រោង FEMS នេះ ជាផ្នែកមួយក្នុងចំណោមផ្នែកធំៗទាំង០៥ របស់កម្មវិធីគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ (FMMP) ដែលជាកម្មវិធីមួយ មានវិសាលភាពក្នុងតំបន់ និងមានរយៈពេលវែង ដើម្បីការពារនិងកាត់បន្ថយផលប៉ះពាល់អាក្រក់ដែលបណ្តាលមកពីទឹកជំនន់ ទៅលើជីវភាពរបស់ប្រជាជនឱ្យបានក្នុងកម្រិតអប្បបរមា និងថែរក្សាបរិស្ថាននៃទឹកជំនន់ឱ្យនៅគង់វង្សល្អ ។*

*នៅប្រទេសកម្ពុជា គម្រោងពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់(FEMS) បានជួយកសាងសមត្ថភាពក្នុងស្ថាប័នពាក់ពន្ធ័ និង ធ្វើអន្តរាគមន៏នៅក្នុងខេត្តគោលដៅទាំងពីរ គឺខេត្តព្រៃវែង និងខេត្តកណ្តាល ដើម្បីឱ្យស្ថាប័នពាក់ពន្ធ័ទាំងនោះមានសមត្ថភាពខ្ពស់លើការងារគ្រប់គ្រងគ្រោះទឹកជំនន់។ សកម្មភាពសំខាន់ៗចំនួន ០៥ ដែលបានអនុវត្តនៅក្រោមគំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS) រួមមាន : - ការរៀបចំ និង ការអនុវត្តន៏កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់នៅក្នុងខេត្ត និង ស្រុកគោលដៅដែលបានជ្រើសរើស ត្រូវបានសម្របសម្រួល, -សមត្ថភាពថ្នាក់ជាតិ ដើម្បីគាំទ្រការរៀបចំ និងការអនុវត្តន៏កម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយទឹកជំនន់ ត្រូវបានរៀបចំបន្ថែមទៀត, -យុទ្ធនាការផ្សព្វផ្សាយបង្កើនការយល់ដឹងពីគ្រោះភ័យនៃទឹកជំនន់នៅក្នុងស្រុកនិងខេត្តគោលដៅត្រូវបានរៀបចំ, -ការចែករំលែកចំណេះដឹងប្រចាំតំបន់ត្រូវបានសម្របសម្រួលនិង-ការត្រៀមបង្ការសម្រាប់កិច្ចសហប្រត្តិបត្តិការឆ្លងដែនរវាងខេត្តជាប់ព្រំដែនគ្នា នៅពេលដែលមានគ្រោះអាសន្នកើតឡើងត្រូវបានសម្របសម្រួល ។*

## សេចក្ដីផ្ដើម

នៅតាមបណ្ដាប្រទេសជាច្រើន គ្រូបង្រៀនត្រូវបានទទួលស្គាល់ដោយសាធារណៈជនទូទៅថាជាប្រភពធនធានដ៏សំខាន់បំផុតក្នុងការទទួល/ផ្ដល់ព័ត៌មានផ្សេងៗ។ ជាក់ស្ដែងកុមារតូចៗត្រូវបានបញ្ជូនឱ្យទៅរៀននៅសាលា ដូចនេះពួកគេនឹងរៀនសូត្រពីគ្រូៗរបស់ពួកគេ ។ នៅក្នុងប្រទេសកម្ពុជា គ្រូបង្រៀនត្រូវបានគេគោរពជាខ្លាំង រីឯសាលារៀនគឺជាធនធានដ៏សំខាន់មួយរបស់សហគមន៍ ព្រោះថាវាមិនគ្រាន់តែជាកន្លែង សម្រាប់រៀនតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាកន្លែងសម្រាប់ស្នាក់នៅជាបណ្ដោះអាសន្ននៅពេលមានទឹកជំនន់កើតឡើងផងដែរ។ ជាឧទាហរណ៍ នៅតាមបណ្ដាភូមិនានាក្នុងទីជនបទក្នុងប្រទេសកម្ពុជា គេបានប្រើប្រាស់សាលារៀនជាទីទួលសុវត្ថិភាពរបស់ពួកគេនារដូវទឹកជំនន់។ នៅតាមបណ្ដាប្រទេសជាច្រើនទៀតដែរ គុណតម្លៃរបស់គ្រូបង្រៀន និងមន្ត្រីផ្នែកសិក្សាធិការ ត្រូវបានគេទទួលស្គាល់ថា ជាអ្នកផ្សព្វផ្សាយពតិមាន រឺក៏ជាអ្នកផ្ដល់ទំនាក់ទំនងអំពីគ្រោះភ័យនៃគ្រោះមហន្តរាយយ៉ាងមានប្រសិទ្ធិភាព។

ដូច្នេះការសម្រេចចិត្តប្រើប្រាស់ធនធានសាលារៀន និងគ្រូបង្រៀនជាបណ្ដាញព័ត៌មានផ្សព្វផ្សាយព័ត៌មានដំបូង សំរាប់បំរើឱ្យការងារចូលរួមកាត់បន្ថយគ្រោះភ័យនៃទឹកជំនន់ គឺវាពុំមានអ្វីជាការពិបាកនឹងអនុវត្តនោះទេ។ គ្រូបង្រៀនទាំងឡាយគឺជាធនធានដ៏ប្រសើរមួយ ក្នុងការផ្ដល់នូវវិធានការសុវត្ថិភាពទឹកជំនន់ទៅដល់សិស្សានុសិស្ស ដោយសារពួកគេជាក្រុមមួយ ដែលងាយរងគ្រោះបំផុតនៅក្នុងសហគមន៍ ។

ការផ្សព្វផ្សាយពត័មាន ស្ដីពីការការពារគ្រោះទឹកជំនន់តាមរយៈសិស្សានុសិស្ស មិនត្រឹមតែបានដោះស្រាយនូវ ភាពងាយរងគ្រោះដល់ពួកគេដោយផ្ទាល់នោះទេ ប៉ុន្តែថែមទាំងបានជួយនៅពេលដែលពួកគេធំឡើងឱ្យក្លាយទៅជាសមាជិករបស់សហគមន៍នាពេលអនាគត ដោយការប្រើប្រាស់នូវជំនាញនិងចំណេះដឹងដែលពួកគេធ្លាប់មានកាលពីវ័យកុមារដើម្បីចូលរួមកាត់បន្ថយផលប៉ះពាល់បណ្ដាលមកពីគ្រោះទឹកជំនន់ ។

កម្មវិធីបានកំណត់សកម្មភាពសំខាន់ៗដែលត្រូវការអនុវត្ត ដូចជា ការបើកវគ្គបណ្ដុះបណ្ដាលដល់គ្រូបង្រៀន និងអ្នកអប់រំដទៃទៀត អំពីការកាត់បន្ថយគ្រោះភ័យនៃទឹកជំនន់ និងវិធានការសុវត្ថិភាពទឹកជំនន់នានា ដើម្បីជួយផ្សព្វផ្សាយនូវចំណេះដឹង និងជំនាញ ដែលទទួលបានពីវគ្គទៅដល់កុមារ និងសហគមន៍ឱ្យបានទូលំទូលាយតាមរយៈការតស៊ូមតិ និងបញ្ច្រាបកម្មវិធីកាត់បន្ថយគ្រោះភ័យនៃទឹកជំនន់ទៅក្នុងកម្មវិធីសិក្សា ដោយធ្វើឱ្យប្រាកដថា គំនិតផ្ដួចផ្ដើមទាំងនេះ ត្រូវបានអនុវត្តប្រកបដោយនិរន្តរភាព និងបន្តទៅកន្លែងដទៃទៀតនាពេលអនាគត ។

## វិធានសំខាន់ៗសម្រាប់អនុវត្ត

ដើម្បីឆ្លើយតបទៅនឹងគោលដៅទាំងនេះ គំរោងបានកំណត់បាននូវនីតិវិធី ដោយចាប់ដំណើរការអនុវត្តនីសកម្មភាពការងារជាមួយដៃគូពាក់ពន្ធ័សំខាន់ៗនៅនឹងមូលដ្ឋាន ដើម្បីលើកកំពស់ការយល់ដឹង និងភាពអាចទទួលយកបានរបស់ពួកគេលើការងារកាត់បន្ថយគ្រោះភ័យនៃទឹកជំនន់ តាមរយៈសិក្ខាសាលាផ្សព្វផ្សាយ ដើម្បីរៀបចំបង្កើតវិធីសាស្ត្រ និងឧបករណ៏ងាយៗហើយមានលក្ខណៈសមស្រប សំរាប់ជាជំនួយដល់គ្រូបង្រៀនក្នុងការផ្ដល់ចំណេះដឹងទាក់ទងនឹងការកាត់បន្ថយគ្រោះភ័យនៃទឹកជំនន់ទៅដល់កូនសិស្សសាលា និង តាមរយៈការរៀបចំឱ្យមានវគ្គបណ្ដុះបណ្ដាលដល់គ្រូបង្រៀន គ្រូទទួលបន្ទុកថ្នាក់ និងមន្ត្រីផ្នែកសិក្សាធិការទាំងឡាយណាដែលទទួលខុសត្រូវលើការរៀបចំកម្មវិធី សិក្សារបស់សាលា។

"វាមានសារៈសំខាន់ និង ងាយស្រួលណាស់ក្នុងការបង្រៀនមនុស្សក្មេងៗពីវិធានការការពារគ្រោះទឹកជំនន់ ព្រោះពួកគេអាចទទួលបាននូវព័ត៌មានកាន់តែច្រើន... ហើយពេលពួកគេធំឡើងការងារទាំងនេះនឹង ក្លាយជាការងារធម្មតារបស់ពួកគេដែលធ្លាប់បានជួបប្រទះរួចជាស្រេច" ។
(លោក លាក់ សាម៉ន ប្រធានរដ្ឋបាលនៃមន្ទីរអប់រំយុវជន និងកីឡាខេត្តព្រៃវែង)

### ការកៀងគរដៃគូអនុវត្តសំខាន់ៗ

ការកៀងគរ និងការទទួលបានឆន្ទៈពីដៃគូអនុវត្តសំខាន់ៗនៅនឹងមូលដ្ឋាន ដើម្បីរៀបចំគោលគំនិតយល់ដឹងពីការកាត់បន្ថយគ្រោះភ័យនៃទឹកជំនន់មិនមានបញ្ហាអ្វីចោទឡើងនោះទេ ព្រោះគោលគំនិតនេះជាផ្នែកនៃកម្មវិធីដ៏ទូលំទូលាយមួយសំដៅដល់ការពង្រឹងសមត្ថភាពមូលដ្ឋានក្នុងការឆ្លើយតបទៅនឹងគ្រោះទឹកជំនន់ ។

នៅពេលគោលគំនិតយល់ដឹងនេះត្រូវបានចាប់ផ្ដើមអនុវត្តឡើងនោះ ការខិតខំតស៊ូមតិនិងធនធានសំខាន់ៗទាំងឡាយក៏ត្រូវបានរៀបចំរួចជាស្រេចក្នុងការបង្កើនការយល់ដឹងដល់អាជ្ញាធរនៅមូលដ្ឋាន។ ហេតុផល និងគោលការណ៏គ្រឹះ ក៏ដូចជាគោលគំនិតសំខាន់ៗនៃការកាត់បន្ថយគ្រោះភ័យទឹកជំនន់ ក៏ត្រូវបានយល់ដឹងរួចជាស្រេចដែរពីដៃគូអនុវត្តសំខាន់ៗរបស់គំរោង ជាពិសេសអាជ្ញាធរថ្នាក់ខេត្ត និងស្រុកដែលរួមមានទាំងគ្រូបង្រៀនផងដែរ ។

គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់(FEMS) បានដំណើរការពង្រឹងប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយខេត្តដែលដឹកនាំដោយ "គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត (PCDM) ក្នុងនោះរាប់បញ្ចូលទាំងមន្ទីរពាក់ព័ន្ធជុំវិញខេត្តទាំងអស់ ជាពិសេសមន្ទីរអប់រំ និង មន្ទីរសុខាភិបាល...ជាដើម ។

ការអនុវត្តនីកម្មវិធីសុវត្ថិភាពទឹកជំនន់តាមសាលារៀន គឺជាផ្នែកមួយនៃការអនុវត្តនីដំបូងរបស់កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់របស់ខេត្ត ។ ដៃគូអនុវត្តសំខាន់ៗដែលចូលរួមក្នុងកម្មវិធី រួមមាន: គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តនិងស្រុក, មន្ទីរអប់រំយុវជន និងកីឡាខេត្ត, នាយកសាលា, គ្រូបង្រៀន និងមន្ត្រីផ្នែកសិក្សាធិការនៅតាមសាលាគោលដៅនីមួយៗរបស់គំរោង ។

លើសពីនេះទៀត អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលមានបទពិសោធន៏ក្នុងវិស័យអប់រំ គឺអង្គការស្រែខ្មែរ ធ្លាប់បានចូលរួមផ្ដល់ជំនួយគាំទ្រផ្នែកបច្ចេកទេសដល់ដៃគូអនុវត្តនៅតាមមូលដ្ឋាននានាក្នុងតំបន់គោលដៅរបស់គំរោង ជាពិសេសដើម្បីធ្វើឱ្យដៃគូទាំងនោះជួយបន្តការអប់រំផ្សព្វផ្សាយទៅតាមសាលារៀនដទៃទៀត ក្រៅពីសាលាគោលដៅទាំង០២ ដែលបានអនុវត្តសាកល្បងកន្លងមកនោះ។

### ការផលិតឯកសារ សំភារៈផ្សព្វផ្សាយ និងឧបករណ៏នានា

ដោយមានការគាំទ្របច្ចេកទេសពីគម្រោងកម្មវិធីដៃគូអនុវត្តនានាអាចប្រមូលបាននូវព័ត៌មានចំណេះដឹងនិងសំភារៈផ្សព្វផ្សាយស្ដីពីការកាត់បន្ថយគ្រោះភ័យនៃទឹកជំនន់ ដើម្បីធ្វើការពិនិត្យកែសម្រួលឡើងវិញ ធ្វើយ៉ាងណាឱ្យមានលក្ខណៈសមស្របទៅតាមស្ថានភាពជាក់ស្ដែងរបស់មូលដ្ឋាន។ ចំពោះដំណើរការនៃការផលិត និងអនុវត្តមានដូចខាងក្រោម :

- ឃីតសំភារៈផ្ដល់ពតិមានពីគ្រោះទឹកជំនន់ "ឃីតសំភារៈផ្ដល់ពតិមានពីគ្រោះទឹកជំនន់" ត្រូវបានរៀបចំ និងផលិតឡើងសំរាប់ប្រើប្រាស់ជាមូលដ្ឋានគ្រឹះនៃពតិមារបស់គ្រូបង្រៀន ក្នុងការផ្សព្វផ្សាយចំណេះដឹងពីការកាត់បន្ថយគ្រោះ




*ពតិមានអប់រំពីគ្រោះទឹកជំនន់ ( ខាងលើ) និងសៀវភៅទឹកជំនន់ ( ខាងក្រោម) ត្រូវបានផលិតឡើងសំរាប់គ្រូបង្រៀន ដើម្បីអោយពួកគេអាចធ្វើយុទ្ធនាការយល់ដឹងពីគ្រោះភ័យនៃគ្រោះមហន្តរាយនៅក្នុងចំណោមកូនសិស្សរបស់ពួកគេ ។*




ភ័យនៃទឹកជំនន់ទៅដល់សិស្សានុសិស្សក្នុងការផលិតសំភារៈផ្តល់ពតិមានគ្រោះទឹកជំនន់នេះ គឺត្រូវបានធ្វើការត្រួតពិនិត្យយ៉ាងហ្មត់ចត់ដើម្បីធានាឱ្យពតិមានមានលក្ខណៈត្រឹមត្រូវ និងមានប្រយោជន៍យ៉ាងពិតប្រាកដ ។

គ្រប់ពតិមាននិងសំភារៈផ្តល់ពតិមានទាំងអស់សំរាប់បំរើសកម្មភាពកាត់បន្ថយគ្រោះទឹកជំនន់ ត្រូវបានរៀបចំដោយផ្អែកលើឧទាហរណ៏ ដែលមានស្រាប់ពីបទពិសោធន៏លើការអនុវត្តន៏ល្អកន្លងមក (សំភារៈ និងឧបករណ៏ ដែលបានរៀបចំ និងធ្វើការសាកល្បងជាមួយអ្នកភូមិ និងជាមួយអង្គការជាតិ និងអន្តរជាតិនានា) ។ ចំពោះសំភារៈផ្តល់ពតិមានគ្រោះទឹកជំនន់រួមមាន :

- កូនសៀវភៅស្តីពីវិធានការកាត់បន្ថយគ្រោះភ័យនៃទឹកជំនន់នៅតាមគ្រួសារ ( មុនពេល អំឡុងពេល និងក្រោយទឹកជំនន់)
- ខ្សែវីដេអូ មានចំណងជើងថា "ការរស់នៅជាមួយទឹកជំនន់" ជាមួយនឹងកូនសៀវភៅមួយដែលនិយាយសង្ខេបពីពតិមាននៅក្នុងខ្សែវីដេអូ ។
- កូនសៀវភៅស្តីពីបញ្ហាសុខភាពពេលទឹកជំនន់ ដែលផ្តល់ជាវិធានការការពារនិងសង្គ្រោះដែលគ្រួសារគួរអនុវត្តដើម្បីចៀសវាងជំងឺផ្សេងៗ ដែលបណ្តាលមកពីគ្រោះទឹកជំនន់ ។

ខណៈពេលដែលសំភារៈមានស្រាប់ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយបែបនេះ គំរោងកម្មវិធីបានជួយគាំទ្រដល់ដៃគូក្នុងការរៀបចំ ការត្រួតពិនិត្យដ៏ហ្មត់ចត់មួយនៃពតិមាន និងឯកសារដែលបានផ្សព្វផ្សាយនេះ ដើម្បីធានាថាឧទាហរណ៏ដែលលើកឡើង និងការអនុវត្តន៏ដែលបង្ហាញនោះមានលក្ខណៈសមស្របទៅនឹងទំនៀមទម្លាប់ ប្រពៃណី សង្គម និងវប្បធម៌ ដែលមានស្រាប់នៅក្នុងមូលដ្ឋាននោះ ។

កូនសៀវភៅទឹកជំនន់នេះ ជាសៀវភៅដែលបានត្រួតពិនិត្យកែតម្រូវនិងកែលំអពីកូនសៀវភៅរបស់អង្គការADPC ដែលបានប្រើប្រាស់នៅក្នុងកម្មវិធីគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយនៅតាមមូលដ្ឋានសហគមន៏កាលពីមុន ។ សៀវភៅនេះណែនាំពីស្ថានភាពទឹកជំនន់នៅក្នុងប្រទេសកម្ពុជា, ផលប៉ះពាល់ និងគ្រោះថ្នាក់ពីទឹកជំនន់, វិធានការដែលគួរធ្វើនៅមុនពេល, អំឡុងពេល និងក្រោយពេលទឹកជំនន់ ។ ក្រៅពីនេះនៅមានឧបករណ៏ពតិមានជាច្រើនទៀត ត្រូវបានផ្តល់ទាក់ទងនឹងការផ្តល់ពតិមានជាមុនពីគ្រោះទឹកជំនន់ ការការពារ និងការឆ្លើយតបទៅនឹងគ្រោះទឹកជំនន់ជាដើម ។

ខ្សែវីដេអូ មានចំណងជើងថា "**ការរស់នៅជាមួយទឹកជំនន់**" បានផលិតដោយសុំការអនុញ្ញាតពីអង្គការអុកស្វាមអង់គ្លេស(Oxfam-GB) នៅក្នុងប្រទេសកម្ពុជាដែលជាអ្នកកែសម្រួលខ្សែវីដេអូនេះចេញពីខ្សែវីដេអូដើមរបស់កាកបាទក្រហមវៀតណាម (VNRC) ស្របតាមតាមបរិបទរបស់ប្រទេសកម្ពុជា ។ អង្គការអុកស្វាមអង់គ្លេស (Oxfam-GB) បានប្រើប្រាស់ខ្សែវីដេអូនេះយ៉ាងទូលំទូលាយក្នុងការអនុវត្តន៏កម្មវិធីរបស់ខ្លួន លើការងារកាត់បន្ថយគ្រោះភ័យនៃទឹកជំនន់នៅតាមមូលដ្ឋានសហគមន៏នានាក្នុងប្រទេសកម្ពុជា ។

គោលលបំណងនៃកម្មវិធីពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS) គឺកាត់បន្ថយភាពងាយរងគ្រោះរបស់កុមារពីទឹកជំនន់តាមរយៈប្រពន្ធ័សាលារៀន ។ ការងារនេះបានប្រព្រឹត្តដោយនៅក្នុងតំបន់ប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ឡាវ ថៃឡង់ដ៏ និងវៀតណាម ។



*លោកងូ យិន ត្រឹងញា ជាគ្រូបង្ហាត់នៅមត្តេយ្យសាលា ពីភាពអាសន្នគ្រោះទឹកជំនន់ វៀតណាម:* " គឺជាផ្នែកមួយនៃកម្មវិធី កន្លែងមើលក្មេងៗ មិនត្រឹមតែថែរក្សាសុវត្ថិភាពដល់កុមារប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាទីរួមបញ្ចូលមុខការងាររបស់មតេយ្យសាលាផងដែរ ។

ដូចនេះនៅក្នុងកម្មវិធីមត្តេយ្យសាលាណាក៏ដោយ ក្រៅពីការផ្តល់ចំណេះដឹងអប់រំលើអនាម័យ អាហារូបត្ថម្ភ ចិត្តសាស្ត្រ និងលក្ខណៈសម្បត្តិដល់កុមារ យើងក៏បង្ហាត់អ្នកថែទាំកុមារអំពីរបៀបធ្វើប្រដាប់ប្រដាក្មេងលេង ដែលមានតម្លៃថោកដោយប្រើប្រាស់ធនធាន ដែលអាចប្រើបាននៅក្នុងសហគមន៏" ។



*លោក លុង វៀន ភុង សាលាបឋមសិក្សា វិញនាន វៀតណាម :* " កាលពីពេលកន្លងមក មុនកម្មវិធីនេះបានចាប់ផ្តើម មានកុមារជាច្រើនបានបាត់បង់ជីវិត ហើយផ្ទះប្រជាពលរដ្ឋណាដែលមិនបានរៀបចំថែទាំត្រៀមបង្ការឱ្យបានមាំទាំនោះ ត្រូវបានបាក់ស្រុតដួលរលំ ។ តែសព្វថ្ងៃនេះ នៅក្នុងសាលារៀន គ្រូបញ្ចូលចំណេះដឹងនេះទៅក្នុងការបង្រៀនរបស់គាត់ ។ សិស្សានុសិស្សពាំនាំយកចំណេះដឹងទាំងនោះទៅផ្ទះ ។ ដូចនេះ វិធីនេះបានធ្វើឱ្យសិស្សទាំងនោះក្លាយទៅជាភ្នាក់ងារដ៏ក្មេងខ្ចី ដែលជាអ្នកអាចជួយរំលែកការងារបានមួយចំណែក ពីក្រសួង/មន្ទីរគ្រប់គ្រងគ្រោះភ័យនៃខ្យល់ព្យុះ និងទឹកជំនន់ " ។



*អ្នកគ្រូ ហង្ស ថាវី បង្រៀនថ្នាក់ទី ៨ នៅកម្ពុជា :* " ក្រោយពីបានទទួលវគ្គបណ្តុះបណ្តាលនេះ ខ្ញុំនឹងយកមេរៀនទាំងនេះបង្រៀនដល់សិស្សានុសិស្សរបស់ខ្ញុំ ហើយខ្ញុំនឹងបង្រៀនពួកគេអំពីរបៀបត្រៀមបង្ការ និង ការការពារខ្លួនពួកគេនៅក្នុងពេលទឹកជំនន់ ដោយមិនបាច់មានជំនួយពីឧបករណ៍បណ្តែតទឹកផ្សេងៗដូចជាអាវពោងជាដើម ។ ដូចគ្នានេះដែរ ខ្ញុំនឹងបង្រៀនពួកគេ អំពីការផ្សព្វផ្សាយចំណេះដឹងទៅដល់មាតាបិតា មិត្តភក្តិ និងសហគមន៏ទាំងមូល ។



*លោកផាន់ង៉ុកធិច បិតាសិស្ស នៅអានយ៉ាង ប្រទេសវៀតណាម :* " នៅក្នុងតំបន់ដីសណ្តរទន្លេមេគង្គយើងរស់នៅជាមួយទឹកជំនន់រយៈពេល ៦ខែ ជារៀងរាល់ឆ្នាំ ប៉ុន្តែកូនៗរបស់ពួកយើងមានសំណាងតិចតួចក្នុងការហែលទឹក ។ តែឥឡូវនេះអាជ្ញាធរមូលដ្ឋានកំពុងរៀបចំមេរៀនហែលទឹក ។ ខ្ញុំនាំកូនស្រី ខ្ញុំមករៀនពីការហែលទឹកនេះដែរ ដូចនេះនាងមិនលង់ទឹកទេ នៅក្នុងរដូវទឹកជំនន់រយៈពេល៦ខែនេះ " ។

សៀវភៅស្តីពី "បញ្ហាសុខភាពពេលទឹកជំនន់" ត្រូវបានផលិត និងកំពុងប្រើប្រាស់សព្វថ្ងៃដោយក្រសួងសុខាភិបាលនៅក្នុងកម្មវិធីសុខភាពសាធារណៈរបស់ខ្លួន ។ សៀវភៅនេះបង្ហាញពីប្រភេទជំងឺ និងការគំរាមកំហែងនានា ដែលបណ្តាលមកពីទឹក និងនិយាយពីវិធានការ ការពារនានា ដែលគួរធ្វើរបស់គ្រួសារនីមួយៗ ។

■ ផ្ទាំងរូបភាព ស្តីពីវិធានការការពារក្មេង

ផ្ទាំងរូបភាពទាំងពីរផ្ទាំងនេះ ត្រូវបានប្រើប្រាស់សម្រាប់យុទ្ធនាការយល់ដឹងពីគ្រោះភ័យនៃទឹកជំនន់ របស់កម្មវិធីពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់(FEMS) ។ឈុតទីមួយ មានផ្ទាំងរូបភាព០៣ ដែលនិយាយពីវិធានការការពារគ្រោះទឹកជំនន់នៅតាមគ្រួសារ នូវអ្វីដែលគួរធ្វើនៅមុនពេល, ក្នុងពេល និងក្រោយពេលទឹកជំនន់ ។ ឈុតទីពីររៀបចំឡើងសម្រាប់កុមារ និងបង្កើនការប្រុងប្រយ័ត្ន ដើម្បីការពារក្មេងកុំឱ្យលង់ទឹកនារដូវទឹកជំនន់ ។

ផ្ទាំងរូបភាពមួយផ្ទាំងទៀត គឺណែនាំទៅដល់ឪពុកម្តាយឱ្យចេះថែរក្សាកូននារដូវទឹកជំនន់ ។ ផ្ទាំងរូបភាពទាំងនេះ ត្រូវបានបោះពុម្ពចំនួន៨០០ផ្ទាំង ដែលបានចែកចាយទៅតាមសាលារៀន និងឃុំគោលដៅ ។ ផ្ទាំងរូបភាពទាំងអស់នេះត្រូវបានកែសម្រួលដូចទៅនឹងផ្ទាំងរូបភាព ដែលបានប្រើប្រាស់ដោយសមាគមសង្គ្រោះកុមាររបស់ប្រទេសវៀតណាមដែរ ។

## សិក្ខាសាលាបណ្តុះបណ្តាលដល់គ្រូបង្រៀន

សិក្ខាសាលានេះ បានរៀបចំសម្រាប់មន្ត្រីអប់រំ, នាយកសាលា និងគ្រូបច្ចេកទេសនៅថ្នាក់ខេត្ត និងស្រុក ( គ្រូបច្ចេកទេស ជាមន្ត្រីដែលទទួលបន្ទុកលើការរៀបចំកម្មវិធីសិក្សាក្នុងសាលា) ។

វគ្គបណ្តុះបណ្តាលចំនួន០៤វគ្គ បានរៀបចំឡើងដោយមានសិក្ខាកាមចំនួន ៧៦នាក់ មកពីស្រុកគោលដៅទាំងបួនរបស់គំរោងរួមមានៈ ស្រុកពាមជរ៍ និងស្រុកស៊ីធរកណ្តាល ក្នុងខេត្តព្រៃវែង និងស្រុកល្វាឯម និងស្រុកលើកដែក ក្នុងខេត្តកណ្តាល ។ នៅក្នុងវគ្គបណ្តុះបណ្តាលទាំងនេះ សំភារៈពតិមានក៏ត្រូវបានបង្ហាញ សម្រាប់ប្រើប្រាស់ជាឯកសារសម្រាប់បំរើឱ្យការងារអប់រំដល់ក្មេងៗ ពីវិធានការកាត់បន្ថយគ្រោះភ័យនៃទឹកជំនន់ ត្រូវបានពិភាក្សាយ៉ាងទូលំទូលាយផងដែរ ។








*គ្រូបង្រៀនបានចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការត្រៀមបង្ការគ្រោះទឹកជំនន់ដែលជាផ្នែករបស់កម្មវិធីសុវត្ថិភាពពីគ្រោះទឹកជំនន់នៅតាមសាលារៀន*

គួរបញ្ជាក់ផងដែរថា វគ្គបណ្តុះបណ្តាលនេះធ្វើឡើងក៏ដើម្បីឱ្យសិក្ខាកាមទាំងអស់ផ្សព្វផ្សាយវគ្គនេះទៅដល់គ្រូបង្រៀននៅក្នុងកម្រិតបឋមសិក្សាផងដែរ ។ គោលបំណងនេះ គឺដើម្បីបង្កើតឡើងនូវធនធានគ្រូបង្រៀនសំរាប់ជួយផ្សព្វផ្សាយបន្តទៅដល់គ្រូបង្រៀននៅតាមសាលាដទៃទៀត ដែលស្ថិតក្នុងខេត្តគោលដៅទាំងពីរខាងលើ ។

កត្តាសំខាន់នៃវគ្គបណ្តុះបណ្តាលនេះ គឺការសម្របសម្រួលនៅក្នុងដំណើរការរៀបចំផែនការដូច្នេះមន្ត្រីនៅតាមសាលា នៅថ្នាក់ខេត្ត និងថ្នាក់ឃុំ បានជួយរៀបចំផែនការមួយដើម្បីផ្សព្វផ្សាយ និងបើកវគ្គបណ្តុះបណ្តាលដល់គ្រូនៅតាមសាលាមិនមែនគោលដៅ ។

វគ្គបណ្តុះបណ្តាលផ្សេងមួយទៀត បានរៀបចំដល់គ្រូនៅសាលាគោលដៅដោយមន្ត្រីថ្នាក់ខេត្តនិងស្រុករបស់មន្ទីរអប់រំយុវជននិងកីឡា,គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ស្រុក (PCDM/DCDM) ដោយមានជំនួយបច្ចេកទេសពីអង្គការមិនមែនរដ្ឋាភិបាលមួយ គឺអង្គការ ស្រែខ្មែរ (SK) ។ ការបង្កើតដៃគូជាមួយអង្គការនេះ ជាចំណែកមួយនៃកិច្ចប្រឹងប្រែងទាំងអស់លើការផ្ទេរចំណេះដឹងនិងជំនាញដល់អង្គការជាតិ និងអន្តរជាតិ ហើយវានឹងធ្វើឱ្យមាននិរន្តរភាពនៃគោលគំនិតនៅក្នុងតំបន់នេះ ។

## ការផ្សព្វផ្សាយនៅតាមថ្នាក់រៀន

កិច្ចតែងការបង្រៀន ត្រូវបានរៀបចំដោយគ្រូ និងគ្រូបច្ចេកទេសប្រចាំសាលា ដើម្បីបង្កើតមូលដ្ឋានគ្រឹះសម្រាប់បង្រៀនដល់សិស្ស ។ សព្វថ្ងៃនេះ វគ្គផ្សព្វផ្សាយការយល់ដឹងពីគ្រោះភ័យនៃទឹកជំនន់ និងការពារក្មេងៗ កំពុងតែដំណើរការជាប្រចាំនៅក្នុងសាលាបឋមសិក្សាកោះរះ នៅក្នុងស្រុកល្វាឯម ខេត្តកណ្តាល និងសាលាបឋមសិក្សាវាលរបងលើ នៅក្នុងស្រុកពាមជរ៍ ខេត្តព្រៃវែង ដែលជាសាលាគោលដៅរបស់កម្មវិធី ។

វគ្គផ្សព្វផ្សាយនេះ បានដាក់បញ្ចូលទៅក្នុងមុខវិជ្ជាសិក្សាសង្គម និងបំណិនជីវិត (ការថែរក្សាសុខភាព, ការធ្វើម្ហូប, ការដេរប៉ាក់, ការថែទាំអ្នកជំងឺ... ជាដើម) ដែលបានបង្រៀនមួយសប្តាហ៍ម្តង ហើយមានរយៈពេលមួយម៉ោងកន្លះដែលបង្រៀននៅក្នុងថ្នាក់ទី១ដល់ទី៦ ។ គ្រូអាចប្រើប្រាស់នូវវិធីសាស្ត្របង្រៀនផ្សេងៗ និងអាចធ្វើការកែប្រែនូវវិធីសាស្ត្របង្រៀនដែលពួកគេគិតថាវាមានលក្ខណៈសមរម្យ ។ កូនសិស្ស សាលាបឋមសិក្សាដែលនៅក្នុងសាលាគោលដៅទាំងពីរខាងលើទទួលបាននូវអត្ថប្រយោជន៍ដោយផ្ទាល់ពីកម្មវិធីនេះ ។

គ្រូជាច្រើនក៏បានប្រាប់ពីការផ្លាស់ប្តូរអត្តចរិករបស់សិស្សពួកគេថា: "យើងសង្កេតឃើញថាសិស្សភាគច្រើនបានយកឧបករណ៍ទាំងឡាយណា ដែលអាចអណ្តែតទឹកមកតាមខ្លួនខណៈពេលពួកគេមកសាលារៀនម្តងៗនៅរដូវទឹកជំនន់" ។ ទម្លាប់ចាស់ៗ ដែលកូនសិស្សទាំងនោះអុំទូកមកសាលារៀនដោយខ្លួនឯង ក៏សង្កេតឃើញថាមានការថយចុះជាច្រើនផងដែរដោយមានឪពុកម្តាយជាអ្នកជូនមក និងទទួលយកទៅវិញពីសាលារៀន ។

សកម្មភាពនៅតាមសាលាជាច្រើនទៀត ត្រូវបានធ្វើផងដែរនៅមុនពេលមានទឹកជំនន់ ។ ជាឧទាហរណ៍នៅក្នុងអំឡុងពេលក្រោយរដូវទឹកជំនន់ ការផ្សព្វផ្សាយណែនាំតែងបានធ្វើជាប្រចាំនៅពេលគោរពទង់ជាតិ ហើយគ្រូៗក៏បានរៀបចំផែនការសម្រាប់រៀបចំថ្ងៃពិសេសជាប្រចាំមួយ ដែលហៅថាទិវាសុវត្ថិភាពពីគ្រោះភ័យនៃទឹកជំនន់ដែលទាក់ទងនឹងសកម្មភាពអប់រំបង្កើនការយល់ដឹងពីគ្រោះទឹកជំនន់ ។









## ការបញ្ជ្រាបកម្មវិធីសុវត្ថិភាពគ្រោះទឹកជំនន់ទៅក្នុងកម្មវិធីសិក្សានៅតាមសាលារៀន



គ្រូបង្រៀនគឺជាប្រភពនៃពត៌មានដែលអាចជឿជាក់បាន ។រូបភាពខាងលើនេះបង្ហាញពីគ្រូបង្រៀននៅខេត្តព្រៃវែងពន្យល់ពីវិធានការសុវត្ថិភាពពីគ្រោះទឹកជំនន់ដល់កូនសិស្សរបស់គាត់ ។

កិច្ចប្រឹងប្រែងដើម្បីបញ្ចូលការយល់ដឹងពីគ្រោះភ័យនៃទឹកជំនន់ទៅក្នុងកម្មវិធីសិក្សាសាលារៀន ត្រូវបានរៀបចំតាមរយៈការចូលរួមរបស់គ្រូបច្ចេកទេសនៅក្នុងសកម្មភាព និងដំណើរការទាំងអស់ដែលបានរៀបចំឡើង ។

គ្រូបច្ចេកទេស ត្រូវទទួលខុសត្រូវក្នុងការរៀបចំមាតិកា និងរបៀបបង្រៀន ដែលត្រូវប្រើឱ្យបានសមស្របទៅនឹងអ្វីដែលមន្ទីរអប់រំ យុវជននិងកីឡាខេត្តបានរៀបចំ ។ គ្រូបច្ចេកទេស ក៏ត្រូវណែនាំ និងជួយគាំទ្រដល់គ្រូផ្សេងៗទៀតក្នុងការរៀបចំកិច្ចតែងការសម្រាប់បង្រៀន និងការរៀបចំការផ្សព្វផ្សាយការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់ និងរៀបចំម៉ោងសម្រាប់បង្រៀនដល់សិស្សពីវិធានការការពារក្មេងៗពេលទឹកជំនន់ និងជួយជំរុញឱ្យគ្រូប្រើប្រាស់ឯកសារអប់រំ, ពតិមាន និងឯកសារទំនាក់ទំនង ដែលបានរៀបចំនោះផងដែរ ។

ទោះបីជាគម្រោងផ្សេងគ្នាក៏ដោយ ក៏មជ្ឈមណ្ឌលត្រៀមបង្ការគោះមហន្តរាយអាស៊ុ(ADPC) បានរៀបចំបង្កើតនូវគោលគំនិតដ៏ធំមួយនៅថ្នាក់ជាតិក្នុងការបញ្ចូលកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងកម្មវិធីសិក្សារបស់សាលារៀន តាមរយៈកម្មវិធី " ការបញ្ចូលកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងកម្មវិធីអប់រំ "។ នៅក្រោមកម្មវិធីនេះ សាលាគោលដៅចំនួនពីររបស់គម្រោងកម្មវិធីពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS) ត្រូវបានកំណត់ជាសាលាគោលដៅសម្រាប់សាកល្បងនូវមេរៀននៃការកាត់បន្ថយគ្រោះភ័យ នៃគ្រោះមហន្តរាយ ដែលបានរៀបចំដោយនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា របស់ក្រសួងអប់រំ យុវជន និងកីឡា ។



មន្ត្រីមកពីក្រសួងអប់រំ យុវជន និងកីឡា ធ្វើការសង្ខេបទៅដល់គ្រូបង្រៀននៅខេត្តព្រៃវែងស្តីពីការបញ្ជ្រាបមុខវិជ្ជាកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ទៅក្នុងកម្មវិធីសិក្សានៅតាមសាលារៀន

### មេរៀន និងបទពិសោធន៍ ដែលទទួលបានពីការអនុវត្តន៍

- ការផ្សព្វផ្សាយពតិមាន និងចំណេះដឹងដោយប្រើប្រាស់ធនធានសាលា និងគ្រូបង្រៀន ប្រសិនបើវាមាននិរន្តរភាពនោះ វានឹងមានមូលដ្ឋាន ដ៏រឹងមាំសម្រាប់ការងារកាត់បន្ថយភាពងាយរងគ្រោះដោយទឹកជំនន់នៅក្នុងសហគមន៍ ។
- ការផ្សព្វផ្សាយការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់តាមរយៈសាលារៀនវាមានប្រសិទ្ធភាពណាស់ព្រោះគ្រូបង្រៀននិងបុគ្គលិកនៅក្នុងសាលា( អ្នកធ្វើសារទំនាក់ទំនង) ត្រូវបានគេគិតថា ជាអ្នកដែលគួរឱ្យជឿទុកចិត្តពីសំណាក់កូនសិស្ស និងសហគមន៍ទាំងមូល ( អ្នកទទួលសារ ឬអ្នកត្រងត្រាប់ស្តាប់) ។
- សារដែលបានបញ្ជូន ត្រូវតែអាស្រ័យលើចំណេះដឹងនៅមូលដ្ឋានដែលពួកគេមាន និងផ្អែកលើមូលដ្ឋាននៃទំនៀមទម្លាប់ និងប្រពៃណី របស់សង្គមក្នុងមូលដ្ឋាននោះ ប្រសិនបើទាំងនេះអាចធ្វើទៅបាន នោះវានឹងមានការយល់ដឹងច្រើន និងកាន់តែមានប្រសិទ្ធភាព ។
- ប្រសិនបើឱ្យក្មេងៗ និងយុវជនដើរតួនាទីធ្វើជាអ្នកបញ្ជូនសារទៅដល់គ្រួសារ និងសហគមន៍របស់ពួកគេកាន់តែច្រើន នោះក្មេងៗអាចកាន់តែទទួលបាននូវចំណេះដឹង និងជំនាញថ្មីៗក៏កាន់តែច្រើនផងដែរ ។
- យើងត្រូវការធនធាន និងពេលវេលាច្រើនណាស់ ក្នុងការរៀបចំពតិមានយល់ដឹងពីគ្រោះភ័យនៃទឹកជំនន់ និង សម្រាប់រៀបចំយុទ្ធនាការផ្សព្វផ្សាយ ប៉ុន្តែវាអាចនឹងមាន ភាពងាយស្រួលឡើងវិញ ខណៈវគ្គផ្សព្វផ្សាយនេះត្រូវបានរៀបចំបន្តនៅតាមបណ្តាសាលាដទៃទៀត ។
- ជំហាននៃការរៀបចំយុទ្ធនាការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់នៅតាមសាលារៀន អាចប្រើរយៈពេលខ្លី ប្រសិនបើមានការកែសម្រួលឯកសារអប់រំ, ពតិមាន និងឯកសារទំនាក់ទំនងដែលមានស្រាប់ និងវិធីសាស្ត្រស្របតាមលក្ខណៈជាក់ស្តែងនៅតាមមូលដ្ឋាន ។
- គោលនយោបាយរបស់រាជរដ្ឋាភិបាលជាតិ លើការបញ្ចូលវិធានការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងកម្មវិធីសិក្សារបស់សាលា រួមទាំងការកសាងសមត្ថភាពរបស់មន្ត្រីនៅក្នុងសាលារៀន និងមន្ត្រីគ្រប់គ្រងគ្រោះមហន្តរាយនៅតាមមូលដ្ឋាន វាបានបង្កើត បរិយាកាសអំណោយផលមួយដែលនឹងអាចធ្វើឱ្យការយល់ដឹង និង ការអប់រំពីគ្រោះភ័យនៃគ្រោះមហន្តរាយ ( ទឹកជំនន់) តាមរយៈសាលា មាននិរន្តរភាព និង អាចផ្សព្វផ្សាយបន្តទៅកាន់តំបន់ដទៃទៀត ។

### សេចក្តីសន្និដ្ឋាន និង ទិសដៅ

ការបង្រៀននៅតាមសាលាលើចំណេះដឹងគ្រោះភ័យនៃទឹកជំនន់និងវិធានការការពារក្មេងៗពេលទឹកជំនន់គឺជាកិច្ចការអនុវត្តន៍ដ៏ល្អព្រោះវាបានឆ្លើយតបទៅនឹងតម្រូវការពិសេសមួយរបស់ក្មេងៗដែលងាយរងគ្រោះខ្លាំង ។ លើសពីនេះទៀត វាក៏បានផ្តល់នូវអត្ថប្រយោជន៍មួយទៀត គឺវាចំណាយថវិកាតិចតួច ហើយអាចរៀបចំបន្តនៅកន្លែងដទៃទៀតបាន ។ ទោះបីជាការបញ្ជូនពតិមាន និងការផ្សព្វផ្សាយ ជាដំណើរការដែលមានបញ្ហាប្រឈមមុខច្រើន និងតែងផ្លាស់ប្តូរជានិច្ច ដែលត្រូវការរយៈពេលយូរក្នុងការត្រួតពិនិត្យក៏ដោយ ក៏ប្រព័ន្ធផ្សព្វផ្សាយ និងសារនេះនៅតែជាតម្រូវការរបស់ជនទូទៅដដែល ។

ដើម្បីឈានទៅសំរេចគោលដៅខាងលើ យន្តការនានាដែលទទួលឱ្យបានពីការចូលរួមមតិយោបល់ពីអង្គការជាតិ-អន្តរជាតិ គួរត្រូវបានរៀបចំ និង អនុវត្តឱ្យមានប្រសិទ្ធិភាពតាមរយៈពតិមាន, ការអប់រំ និង វិធីសាស្ត្របញ្ជូនពតិមាន និងឧបករណ៍នានា ។ ប្រព័ន្ធគ្រប់គ្រង និង ពតិមាន ត្រូវបានចាត់ទុកថាជាសមាសភាពដ៏សំខាន់នៃគោលគំនិតនៅពេលអនាគត ។

ជាចុងក្រោយ តួនាទីរបស់សាលារៀន ដែលជាធនធានរបស់សហគមន៍ នៅក្នុងការបញ្ជូនពតិមានគ្រោះភ័យនៃគ្រោះមហន្តរាយ និងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ គួរតែដាក់បញ្ចូលទៅក្នុងកម្មវិធីកសាងសមត្ថភាពលើការត្រៀមបង្ការគ្រោះមហន្តរាយនិងការរៀបចំផែនការនៅតាមមូលដ្ឋានឃុំ/សង្កាត់ ។ ដូចនេះការប្រើប្រាស់ធនធានសាលារៀននេះ នឹងត្រូវបានគេយកចិត្តទុកដាក់ និងរៀបចំឱ្យបានល្អ ព្រមទាំងមានការថែទាំយ៉ាងជិតដល់ ។


### សេចក្តីថ្លែងអំណរគុណ

សហគមន៍មានសុវត្ថិភាព សូមថ្លែងអំណរគុណចំពោះការចូលរួមចំណែកពីអ្នកទាំងអស់ដូចខាងក្រោមក្នុងការរៀបចំចងក្រងករណីសិក្សានេះ :

លោក Aloysisus Rego ប្រធានក្រុម ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ, ប្រទេសថៃ

លោក Thanongdeth Insisiengmay ប្រធានគ្រប់គ្រងកម្មវិធី ពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ ADPC, ប្រទេសកម្ពុជា

លោក Aslam Perwaiz ប្រធានគ្រប់គ្រងគំរោង, ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ, ប្រទេសថៃ

លោក ជុំ វុទ្ធី , ប្រធានគ្រប់គ្រងគំរោងថ្នាក់ជាតិ, ADPC, ប្រទេសកម្ពុជា

លោក អុល សែន, អ្នកសំរបសំរួលកម្មវិធី, ADPC, ប្រទេសកម្ពុជា

លោក ប៊ី ច័ន្ទតុលា, ជំនួយការគំរោង, ADPC, ប្រទេសកម្ពុជា

លោក Jerome Casals, អ្នកនិពន្ធ

លោក លឹម តារា, អ្នករចនាអត្ថបទ

សហគមន៍មានសុវត្ថិភាព ជាឈុតនៃករណីសិក្សា ដែលបានដកស្រង់យកអនុវត្តន៍ល្អៗមកបង្ហាញទាក់ទងនឹងការត្រៀមបង្ការ និងកាត់បន្ថយ គ្រោះមហន្តរាយ ដែលបានអនុវត្តដោយរាជរដ្ឋាភិបាលនិង អង្គការក្រៅរដ្ឋាភិបាល សំដៅកាត់បន្ថយភាពងាយរងគ្រោះ និង គ្រោះភ័យនៃគ្រោះមហន្តរាយរបស់សហគមន៍ ដែលរស់នៅក្នុងតំបន់ប្រឈមមុខនឹងមុខសញ្ញាបង្កគ្រោះមហន្តរាយនានា ។

ករណីសិក្សានេះ មានទិសដៅផ្តល់ដល់អ្នកធ្វើការសំរេចចិត្ត អ្នកធ្វើផែនការអភិវឌ្ឍន៍ អ្នកអនុវត្តន៍ការងារគ្រប់គ្រងគ្រោះមហន្តរាយ អ្នកដឹកនាំសហគមន៍ និង អ្នកអប់រំនានានូវគំនិតច្នៃប្រឌិត ឧបករណ៍ យុទ្ធសាស្ត្រ និង ជំរើសគោលនយោបាយនានា ដែលបានដកស្រង់ពីបទពិសោធន៍ពិតប្រាកដ ការអនុវត្តន៍ល្អៗ និង មេរៀនល្អៗ ដែលទទួលបានពីតំបន់អាស៊ីប៉ាស៊ីហ្វិច ទាក់ទង នឹងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និង កាត់បន្ថយភាពងាយរងគ្រោះរបស់សហគមន៍ ព្រមទាំងកសាងអោយបាននូវភាពជួយខ្លួនឯងរបស់សហគមន៍ និង ធ្វើអោយមានសង្គម ដែលមានការត្រៀមបង្ការគ្រោះមហន្តរាយបានល្អប្រសើរ ។

ក្នុងដំណាក់កាលទី១នេះ ករណីសិក្សាមួយចំនួនត្រូវបានរៀបចំក្រោមផ្នែកទី៤ "គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS)" នៃកម្មវិធីគ្រប់គ្រង និង កាត់បន្ថយ គ្រោះទឹកជំនន់ (FMMP) របស់គណៈកម្មការទន្លេមេគង្គ ។ ដូចនេះករណីសិក្សានេះបានផ្តោតសំខាន់តែទៅលើការគ្រប់គ្រងគ្រោះភ័យនៃគ្រោះទឹកជំនន់នៅតាមតំបន់ភូមិសាស្ត្រនៃប្រទេស ជាសមាជិកគណៈកម្មការទន្លេមេគង្គ ដែលមាន ប្រទេស កម្ពុជា ឡាវ ថៃឡង់ដ៏និងវៀតណាម ។ទោះបីជាយ៉ាងណាក៏ដោយ បទពិសោធន៍និង ការអនុវត្តន៍ល្អៗដែលទទួលបាន ពីបណ្តាប្រទេសដទៃទាក់ទងនឹងគ្រោះ មហន្តរាយធម្មជាតិនឹងត្រូវដាក់បញ្ចូលបន្ថែម នៅពេលក្រោយៗទៀត ។

គោលបំណងនៃកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ របស់គណៈកម្មាធិការទន្លេមេគង្គ គឺដើម្បីការពារ និងកាត់បន្ថយទុក្ខវេទនារបស់ប្រជាជន និងការខូចខាតសេដ្ឋកិច្ច ដែលបណ្តាលមកពី គ្រោះទឹកជំនន់ និងថែរក្សាបរិស្ថាននៃទឹកជំនន់អោយនៅគង់វង្ស ។ កម្មវិធីគ្រប់គ្រង និង កាត់បន្ថយគ្រោះទឹកជំនន់មាន ៥ផ្នែកសំខាន់ៗដូចខាងក្រោម:

ផ្នែកទី ១ : បង្កើតមជ្ឈមណ្ឌលគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់

ផ្នែកទី ២ : វិធានការណ៍បែបរចនាសម្ព័ន្ធ និងការទប់ស្កាត់គ្រោះទឹកជំនន់

ផ្នែកទី ៣ : ការសំរបសំរួលបញ្ហាគ្រោះទឹកជំនន់ឆ្លងដែន

ផ្នែកទី ៤ : ការពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់

ផ្នែកទី ៥ : ការគ្រប់គ្រងដី

ផ្នែកទី៤ "គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS)" នៃកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ (FMMP) នេះ ត្រូវបានអនុវត្តដោយគណៈកម្មការទន្លេមេគង្គ ដោយជំនួយបច្ចេកទេស ពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី និងឧបត្ថម្ភថវិកាដោយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ប្រទេសអាល្លឺម៉ង់ (GTZ) ដែលបានចាប់ផ្តើមពីខែកញ្ញា ឆ្នាំ២០០៤ ដល់ខែមេសា ឆ្នាំ២០០៨។ តំបន់គោលដៅរបស់គំរោងនេះមាននៅក្នុងប្រទេសកម្ពុជា និងវៀតណាម ដែលប្រទេសនីមួយៗយកខេត្ត២ និងស្រុក៤ ជាតំបន់គោលដៅ ។ ដៃគូររបស់គំរោងនេះ មានគណៈកម្មាធិការជាតិទន្លេមេគង្គ, គណៈ កម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងអាជ្ញាធរមូលដ្ឋានប្រចាំខេត្ត ស្រុក និងឃុំរបស់គេ, មន្ទីរ-ការិយាល័យពាក់ព័ន្ធ, ស្ថាប័នផ្សេងៗ, កាកបាទក្រហម, អង្គការអន្តរជាតិ, អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ, ។ល ។

ចាប់តាំងពីឆ្នាំ ២០០៤ មក គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS) បានសំរេចសមិទ្ធិផលដូចខាងក្រោម:

១-កម្មវិធិត្រៀមបង្ការគ្រោះទឹកជំនន់ នៅក្នុងស្រុកនិងខេត្តគោលដៅត្រូវបានបង្កើត និងអនុវត្ត

២-សមត្ថភាពថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិត្រូវបានបង្កើនក្នុងការគាំទ្រទៅលើដំណើរការបង្កើត និងអនុវត្តកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ តាមរយៈការបណ្តុះបណ្តាលនៅកំរិតមូលដ្ឋាន ស្តីការគ្រប់គ្រង គ្រោះទឹកជំនន់នៅតាមសហគមន៍, ការប៉ាន់ប្រមាណការខូចខាតនិងសេចក្តីត្រូវការ, ការរុករកនិងសង្គ្រោះ, ការគ្រប់គ្រងគ្រោះអាសន្នដល់កុមារតូចៗ, ការបង្ហាត់ហែលទឹកដល់កុមារ ។ល ។ ហើយនិងការចូលរួម ទៅក្នុងការអនុវត្តគំរោង ។

៣-ការផ្សព្វផ្សាយយល់ដឹងជាសាធារណៈស្តីពីវិធានការសុវត្ថិភាពគ្រួសារថ្នាក់មូលដ្ឋានត្រូវបានបង្ហាញ រួមមានការផ្សព្វផ្សាយដល់គ្រូបង្រៀន និងកម្មវិធីសុវត្ថិភាពគ្រោះទឹកជំនន់នៅតាមសាលារៀន, ការកំណត់ពីតំរូវការចាំបាច់របស់ស្ត្រីមេគ្រួសារ, ការសំដែងសិល្បៈ, ចាប៉ីដងវែង, ការចែកផ្សព្វផ្សាយសៀវភៅទឹកជំនន់, ផ្ទាំងរូបភាព ជាដើម ។

៤-ការចែករំលែកបទពិសោធន៍ថ្នាក់មូលដ្ឋាន និងតំបន់ត្រូវបានរៀបចំឡើងតាមរយៈសិក្ខាសាលាជាតិ និងតំបន់ ព្រមទាំងធ្វើការបែងចែកឯកសារបទពិសោធន៍ល្អៗជាច្រើន ។

---

**សំរាប់ពត៌មានបន្ថែម អ្នកអានអាចទាក់ទងអាស័យដ្ឋានដូចខាងក្រោម**


អ្នកសំរបសំរួលកម្មវិធីគ្រប់ គ្រងនិងកាតបន្ថយគ្រោះទឹកជំនន់
មជ្ឈមណ្ឌលគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់,
លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អាគារលេខ ៥៧៦, ផ្លូវជាតិលេខ២, សង្កាត់ចាក់អង្រែក្រោម, ខ័ណ្ឌមានជ័យ, រាជធានីភ្នំពេញ
គេហទំព័រ : www.mrcmekong.org

ប្រធានគ្រប់គ្រងកម្មវិធី, មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី
មជ្ឈមណ្ឌលគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់,
លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អាគារលេខ ៥៧៦, ផ្លូវជាតិលេខ២, សង្កាត់ចាក់អង្រែក្រោម, ខ័ណ្ឌមានជ័យ, រាជធានីភ្នំពេញ
គេហទំព័រ : www.adpc.net email : antonio@adpc.net


---

**ដៃគូរគំរោង**


លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRC)
ប្រអប់សំបុត្រលេខ ៦១០១ អគារលេខ ១៨ បានស៊ីថានេនូវ ខ័ណ្ឌស៊ីកុតថាបុង
ក្រុងវៀងច័ន្ទ ប្រទេសឡាវ
ទូរស័ព្ទ: (៨៥៦) ២១ ២៦៣ ២៦៣ ទូរសារ: (៨៥៦) ២១ ២៦៣ ២៦៤
អ៊ីម៉ែល: mrcs@mrcmekong.org វិបសាយ: http://www.mrcmekong.org

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (CNMC)
ផ្ទះលេខ ២៣ មហាវិថីម៉ៅសេទុង ក្រុងភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ: (៨៥៥) (២៣) ២១៨ ៧២៧ ទូរសារ: (៨៥៥) (២៣) ២១៨ ៥០៦
អ៊ីម៉ែល: cnmcs@cnmc.gov.kh វិបសាយ: http://www.camnet.com.kh/cnmcs

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM)
ផ្លូវលេខ ៥១៦ សង្កាត់ទូលសង្កែ ខ័ណ្ឌឬស្សីកែវ ក្រុងភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ/ ទូរសារ: (៨៥៥) (២៣) ៨៨២ ០៤៥

លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តកណ្តាល (PCDM)
ឃុំដើមមាន ស្រុកតាខ្មៅ ខេត្តកណ្តាល ប្រទេសកម្ពុជា
ទូរសារ: (៨៥៥) (២៣) ៤២៥៥៥៥

លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង (PCDM)
ឃុំកំពង់លាវ ស្រុកកំពង់លាវ ខេត្តព្រៃវែង ប្រទេសកម្ពុជា
ទូរសារ: (៨៥៥) (២៣) ៩៤៤ ៥៤៦

adpc
មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC)
SM Tower, ជាន់ ទី២៤, ៩៧៩/៦៩, Paholyothin, Samsen Nai, Phayathai,
ក្រុងបាងកក, ប្រទេសថៃ
ទូរស័ព្ទ: (៦៦) ២២ ៩៨ ០៦៨១ ដល់ ៩២
ទូរសារ: (៦៦) ២២ ៩៨ ០០១២ ដល់ ១៣
អ៊ីម៉ែល: adpc@adpc.net វិបសាយ: www.adpc.net



ឧបត្ថម្ភដោយ:

gtz Partner for the Future Worldwide
on behalf of:
Federal Ministry for Economic Cooperation and Development

ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស ប្រទេសអាល្លឺម៉ង់ (GTZ)